# សេចក្តីជូនដំណឹង ស្តីពីការបញ្ចៀសចរាចរណ៍គ្រប់ប្រភេទនៅត្រង់ចំណុចស្ពានជ័យជំនះ( ស្ពានមេទឹក ) តភ្ជាប់កំណាត់ផ្លូវជាតិលេខ៥៥ ស្ថិតនៅក្នុងភូមិសាស្ត្រខេត្តពោធិ៍សាត់



**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងសាធារណការ និងដឹកជញ្ជូន**
លេខ: ✓ សក.សជណ.អរហ

## សេចក្តីជូនដំណឹង
## ស្តីពី
## ការបញ្ចៀសចរាចរណ៍គ្រប់ប្រភេទនៅត្រង់ចំណុចស្ពានជ័យជំនះ( ស្ពានមេទឹក ) តភ្ជាប់កំណាត់ផ្លូវជាតិលេខ៥៥ ស្ថិតនៅក្នុងភូមិសាស្ត្រខេត្តពោធិ៍សាត់

ក្រសួងសាធារណការ និងដឹកជញ្ជូន សូមជូនដំណឹងដល់សាធារណជន អ្នកប្រើប្រាស់ផ្លូវថ្នល់ និងអ្នកដឹកជញ្ជូនទាំងអស់ មេត្តាជ្រាបថា នៅថ្ងៃទី១៣ ខែធ្នូ ឆ្នាំ២០២៥ វេលាម៉ោង ៦:០២នាទីព្រឹក យោធាថៃបានប្រើប្រាស់យន្តហោះចម្បាំងប្រភេទ F-16 ចំនួន ២គ្រឿង វាយប្រហារដោយទម្លាក់គ្រាប់បែក ចំនួន ៣គ្រាប់ កាត់ផ្តាច់ស្ពានជ័យជំនះ( ស្ពានមេទឹក ) ចំនួន ២ស្ពាន ( ស្ពានបេតុងថ្មី និងស្ពានដែកចាស់ ) តភ្ជាប់កំណាត់ផ្លូវជាតិលេខ៥៥ ស្ថិតនៅក្នុងភូមិសាស្ត្រខេត្តពោធិ៍សាត់ ដែលទង្វើរបស់យោធាថៃនេះ គឺជាសកម្មភាពរំលោភបំពានដោយខុសច្បាប់យ៉ាងធ្ងន់ធ្ងរលើអធិបតេយ្យជាតិកម្ពុជា និងបានបំផ្លិចបំផ្លាញហេដ្ឋារចនាសម្ព័ន្ធសាធារណៈនៅកម្ពុជា។

ក្រសួងសូមជម្រាបជូនថា ស្ពានជ័យជំនះ( ស្ពានមេទឹក ) មានប្រវែង ១៨០ម៉ែត្រ ទទឹងប្រវែង ១០ម៉ែត្រ ត្រូវបានស្ថាបនាជាស្ពានបេតុងតភ្ជាប់ពីត្រើយម្ខាងទៅត្រើយម្ខាងទៀតនៃស្ទឹងមេទឹក ត្រង់គីឡូម៉ែត្រលេខ ១៦៩+៤០០ នៃគម្រោងសាងសង់ផ្លូវជាតិលេខ៥៥ ដើម្បីបម្រើដល់ការតភ្ជាប់ និងការធ្វើដំណើររបស់បងប្អូនប្រជាពលរដ្ឋ ក៏ដូចជាការដឹកជញ្ជូនគ្រប់ប្រភេទទៅកាន់គោលដៅនានា។

ទន្ទឹមនេះ ក្រសួងសាធារណការ និងដឹកជញ្ជូន បានត្រៀមលក្ខណៈរួចរាល់ និងរង់ចាំការអនុញ្ញាតពីសមរភូមិជួរមុខ ក្នុងការចុះសិក្សាវាយតម្លៃផលប៉ះពាល់ និងការខូចខាត និងធ្វើការជួសជុលឡើងវិញនៅពេលខាងមុខ ហើយក្រសួងនឹងជូនដំណឹងអំពីការធ្វើចរាចរណ៍ជាប្រក្រតីភាពឡើងវិញក្រោយពីការជួសជុលបានបញ្ចប់ជាស្ថាពរ។

អាស្រ័យហេតុនេះ សូម សាធារណជន អ្នកប្រើប្រាស់ផ្លូវថ្នល់ និងអ្នកដឹកជញ្ជូនទាំងអស់ មេត្តាជ្រាបជាព័ត៌មាន និងបញ្ចៀសការធ្វើចរាចរណ៍គ្រប់ប្រភេទឆ្លងកាត់តំបន់ខាងលើ និងសូមចូលរួមអនុវត្តតាមការរៀបចំរបស់អាជ្ញាធរមូលដ្ឋាន៕

ថ្ងៃសៅរ៍ ៨រោច ខែមិគសិរ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩
រាជធានីភ្នំពេញ ថ្ងៃទី១៣ ខែធ្នូ ឆ្នាំ២០២៥

ផ្លូវលេខ៥៩៨ សង្កាត់ច្រាំងចំរេះ២ ខណ្ឌឬស្សីកែវ រាជធានីភ្នំពេញ
ទូរស័ព្ទ-ទូរសារ ៖ (៨៥៥) ២៣ ៤២៦ ៦៤០, ២៣ ៤២៧ ៨៦២